# វ៉ាក់សាំងជំងឺ COVID-19 ស៊េរី Novavax ឆ្នាំ 2023-2024៖ អ្វីដែលអ្នកគួរដឹង

## តើអ្វីជាវ៉ាក់សាំង Novavax?

វ៉ាក់សាំងថ្មីបំផុតដែលអនុញ្ញាតដោយ Food and Drug Administration (FDA, រដ្ឋបាលចំណីអាហារ និងឱសថ) សម្រាប់ជំងឺ COVID-19 ពោលគឺ Novavax គឺខុសពីវ៉ាក់សាំងជំងឺ COVID-19 ផ្សេងទៀតដែលបច្ចុប្បន្នមានផ្ដល់ជូននៅសហរដ្ឋអាមេរិក។ Novavax គឺជាវ៉ាក់សាំងប្រភេទរងនៃប្រូតេអ៊ីនដែលប្រើបច្ចេកវិទ្យាដូចគ្នានឹងវ៉ាក់សាំងដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយផ្សេងទៀតជាយូរណាស់មកហើយ ដូចជា ជំងឺរលាកផ្លូវដង្ហើម ជំងឺរលាកថ្លើមប្រភេទ B និងផ្ដាសាយធំជាដើម។ សម្រាប់អ្នកដែលមិនបានចាក់វ៉ាក់សាំងពីមុនការពារជំងឺ COVID-19 វ៉ាក់សាំង Novavax គឺជាស៊េរីមាន 2 ដូសដែលចាក់មុនក្រោយគ្នា 3 សប្ដាហ៍ និងមានផ្ដល់ជូនបុគ្គលអាយុ 12 ឆ្នាំឡើងទៅ។

## Novavax គឺជាវ៉ាក់សាំងប្រភេទរងនៃប្រូតេអ៊ីនស៊េរីចាស់។

វ៉ាក់សាំងដែលត្រូវបានអនុញ្ញាតនីមួយៗមានប្រសិទ្ធភាពក្នុងការជួយឱ្យប្រព័ន្ធភាពស៊ាំក្នុងរាងកាយរបស់យើងស្គាល់ និងវាយប្រហារវីរុស COVID-19 រីឯវ៉ាក់សាំង Novavax ប្រើបច្ចេកវិទ្យាវ៉ាក់សាំងបែបចាស់ជាងដែលយើងស្គាល់ច្រើនជាង។



- វ៉ាក់សាំងប្រភេទរងនៃប្រូតេអ៊ីនសម្រាប់ជំងឺ COVID-19 មានបំណែក (ប្រូតេអ៊ីន) របស់វីរុសដែលបង្កជំងឺ COVID-19។
- វ៉ាក់សាំងនេះក៏មានសារធាតុបន្ថែម រួមជាមួយជាតិខ្លាញ់ និងជាតិស្ករដើម្បីជួយឱ្យប្រព័ន្ធភាពស៊ាំប្រតិកម្មនឹងវីរុស និងការពារអ្នកនាពេលអនាគត។
- វាមិនមាន mRNA ទេ។

## វ៉ាក់សាំង Novavax ត្រូវបានបញ្ជាក់ថាមានផលប៉ះពាល់តិចតួចបំផុត។

ផលប៉ះពាល់បណ្ដោះអាសន្នរបស់វ៉ាក់សាំង Novavax មិនខុសគ្នាពីផលប៉ះពាល់ដែលកើតមានជាធម្មតារបស់វ៉ាក់សាំងជំងឺ COVID-19 ផ្សេងទៀតទេ។ ឈឺចុកចាប់/ឈឺខ្លួនឡើងក្រហម និងហើមនៅកន្លែងចាក់ថ្នាំ ក៏ដូចជាអស់កម្លាំងខ្លាំង ឈឺសាច់ដុំ ឈឺក្បាល ឈឺសន្លាក់ ចង្អោរ/ក្អួត និងគ្រុនក្ដៅ។ វ៉ាក់សាំងប្រភេទរងនៃប្រូតេអ៊ីនសម្រាប់ជំងឺ COVID-19 មិនអាចបង្កជំងឺ COVID-19 ឬជំងឺផ្សេងទៀតបានទេ។

## តើយើងត្រូវដឹងអ្វីខ្លះ?

រូបមន្តថ្មីសម្រាប់ឆ្នាំ 2023-2024 នៃវ៉ាក់សាំង Novavax ដែលបានបញ្ចូលសារធាតុពង្រឹងប្រព័ន្ធភាពស៊ាំ ដាក់គោលដៅលើវីរុសបំប្លែងខ្លួនថ្មីដែលបច្ចុប្បន្នកំពុងឆ្លងរាលដាល ដើម្បីផ្ដល់ការការពារកាន់តែប្រសើរកុំឱ្យមានផលវិបាកធ្ងន់ធ្ងរដោយសារជំងឺ COVID-19។ យើងក៏បានដឹងដែរថាវ៉ាក់សាំង Novavax៖



- រូបមន្តវ៉ាក់សាំងជំងឺ COVID-19 ដើមត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៅប្រទេសជាច្រើនផ្សេងទៀត រួមទាំងកាណាដា តាំងពីឆ្នាំ 2021 មក។
- មិនមានសារធាតុផ្សំដូចក្នុងវ៉ាក់សាំងផ្សេងទៀតដែលបង្កអាលែកហ្ស៊ីទេ។
- វ៉ាក់សាំងប្រភេទរងដូចជា Novavax មិនប្រើវីរុសរស់ណាមួយឡើយ ហើយក៏មិនអាចកែប្រែ ឬជះឥទ្ធិពលលើហ្សែនរបស់យើងដែរ។

បុគ្គលអាយុ 12 ឆ្នាំឡើងទៅដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យមឬធ្ងន់ធ្ងរ ឬមិនបានចាក់វ៉ាក់សាំង អាចពិចារណាចាក់វ៉ាក់សាំង Novavax សម្រាប់ជំងឺ COVID-19។ បុគ្គលដែលធ្លាប់ចាក់វ៉ាក់សាំងណាមួយសម្រាប់ជំងឺ COVID-19 អាចចាក់ 1 ដូសនៃវ៉ាក់សាំង Novavax (រូបមន្តមានសារធាតុពង្រឹងប្រព័ន្ធភាពស៊ាំឆ្នាំ 2023-2024) យ៉ាងតិច 2 ខែបន្ទាប់ពីចាក់ដូសចុងក្រោយ។ អាចនឹងផ្ដល់ជូន 1 ដូសបន្ថែមសម្រាប់បុគ្គលដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ។

## វ៉ាក់សាំងនៅតែជាជម្រើសល្អបំផុត។

មិនមានវ៉ាក់សាំងថ្មីឆ្នាំ 2023-2024 សម្រាប់ជំងឺ COVID-19 ណាមួយមានអាទិភាពជាងវ៉ាក់សាំងមួយទៀតនោះទេ។ មិនថាជាវ៉ាក់សាំងម៉ាកអ្វីទេ ការចាក់វ៉ាក់សាំងគឺជាការការពារល្អបំផុតពីជំងឺ COVID-19 និងផលប៉ះពាល់របស់វា។ សូមពិគ្រោះជាមួយអ្នកផ្ដល់សេវារបស់អ្នកថាតើជម្រើសមួយណាល្អបំផុតសម្រាប់អ្នក។




DOH 825-052 November 2023 Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀតទសូមហៅទូរសព្ទមកលេខទ1-800-525-0127 ។ អតិថិជនដែលថ្លង់ ឬស្ដាប់មិនសូវឮសូមទូរសព្ទទៅលេខ711 (Washington Relay) ឬផ្ញើអ៊ីមែលទៅទ doh.information@doh.wa.gov។